#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ជំពូកទី៥៖ ការចូលរួមជាសាធារណៈ

៥.១ សេចក្តីផ្តើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង តម្រូវឱ្យមានការចូលរួមជាសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ដើម្បីឱ្យមានភាពត្រឹមត្រូវ និងអាចទទួលយកបាន។ ការសិក្សានេះ **ក្រុមហ៊ុន គ្រីអេធីវ គ្រីនឌីហ្សាញ** (Creative Green Design) បានចុះធ្វើការសម្ភាសជាមួយក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ម្ចាស់គម្រោង និងប្រជាជនជុំវិញតំបន់គម្រោង ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញ។ ការសម្ភាស និងពិគ្រោះយោបល់នេះ ដើម្បីទទួលបានសំណួរ សំណូមពរ និងអនុសាសន៍ផ្សេងៗក្នុងការជួយកែលម្អ បញ្ចៀស និងកាត់បន្ថយផលប៉ះពាល់ពីគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលនេះ ឱ្យនូវកម្រិតអប្បបរមា និងអាចទទួលយកបាន។

ការចូលរួមជាសាធារណៈត្រូវបានធ្វើឡើង ដើម្បីឱ្យសាធារណៈជនពាក់ព័ន្ធបានដឹងថាមានក្រុមហ៊ុន ALEX CORPORATION មានគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល នៅក្នុងតំបន់របស់ពួកគាត់។ ម្យ៉ាងវិញទៀត ការចូលរួមជាសាធារណៈនេះតម្រូវឱ្យស្ថាប័នពាក់ព័ន្ធទាំងឡាយធ្វើការផ្តល់មតិយោបល់សម្រាប់កែលម្អ ផ្តល់សំណូមពរ និងស្តាបនាក្នុងការជួយសម្រួលដល់ការអនុវត្តគម្រោងឱ្យបានល្អប្រសើរ មានភាពរលូន និងមានប្រសិទ្ធិភាពឱ្យស្របទៅតាមបរិបទអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។

ការចូលរួមជាសាធារណៈ ត្រូវការជាចាំបាច់សម្រាប់ធ្វើការវាយតម្លៃលើហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលមានឥទ្ធិពលលើកត្តាសេដ្ឋកិច្ចសង្គម បរិស្ថានធម្មជាតិ សហគមន៍ទាំងមូលដ្ឋាន តាមរយៈគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។ ដូច្នេះទាមទារឱ្យមានការចូលរួមជាសាធារណៈដែលផ្តោតសំខាន់លើការចុះផ្សាយ ស្ទាបស្ទង់មតិ ការជួបពិភាក្សាជាមួយមន្ទីរ/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីទទួលបាននូវគំនិតរិះគន់ យោបល់គាំទ្រ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ និងអនុសាសន៍នានា ដែលអាចជាប្រភពទិន្នន័យមួយដ៏សំខាន់ក្នុងការសម្រេចចិត្ត។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនៃគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលនេះ ក្រុមហ៊ុនទីប្រឹក្សាបានធ្វើការពិគ្រោះយោបល់ជាមួយ អាជ្ញាធរ មន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ និងប្រជាជនក្នុងខេត្តព្រះសីហនុ ខេត្តកំពុងស្ពឺ និងខេត្តកោះកុង។

Draft

៥.២ គោលបំណងនៃការពិគ្រោះយោបល់

គោលបំណងនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជនជាមួយក្រសួង មន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនមានដូចតទៅ៖

- ផ្សព្វផ្សាយដល់សាធារណៈជន និងអ្នកដែលពាក់ព័ន្ធនឹងគម្រោងទាំងអស់ឱ្យបានដឹងឮពីគោលបំណងរបស់គម្រោងសាងសង់ និងបានដឹងឮថាមានគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល មួយក្នុងតំបន់របស់គាត់។
- ដកស្រង់មតិយោបល់ចូលរួមសហការ និងការគាំទ្រពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋានលើគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់នេះ ដើម្បីឱ្យការអភិវឌ្ឍនេះដំណើរការទៅបានរលូន។
- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ ការងឿងឆ្ងល់របស់មន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ និងប្រជាជនចំពោះគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់នេះ និងការបកស្រាយរបស់ក្រុមហ៊ុនពោលគឺរកវិធីសាស្ត្រសម្របសម្រួល និងកែលម្អដែលអាចទទួលយកបានទាំងសងខាង។

៥.៣ វិធីសាស្ត្រនៃការប្រឹក្សាយោបល់

Draft

ការប្រឹក្សាពិគ្រោះយោបល់ជាសាធារណៈ បានធ្វើឡើងដំបូងជ្រើសរើសខេត្តចំនួនពីរដែលឆ្លងកាត់ច្រើនដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលនេះ គឺទី១ បានធ្វើឡើងនៅខេត្តព្រះសីហនុ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ ដើម្បីស្នើសុំ និងពិគ្រោះយោបល់ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងទី២ ធ្វើឡើងនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ ដើម្បីប្រជុំពិភាក្សាពិគ្រោះយោបល់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងដែលមានការចូលរួមពីមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ។

វិធីសាស្ត្រប្រជុំពិភាក្សា និងពិគ្រោះយោបល់នេះមានការចូលរួមពីសំណាក់សាលាខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សុរិយោដី អគ្គិសនីខេត្ត ពន្ធដាខេត្ត និងស្រុកដែលពាក់ព័ន្ធ ព្រមទាំងតំណាងក្រុមហ៊ុន Alex Corporation និងក្រុមហ៊ុន ត្រីអេធីវ ហ្គ្រីនឌីហ្សាញ។

រីឯប្រជាជនត្រូវបានប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍តាមគេហដ្ឋាន ដោយជ្រើសរើស ប្រជាជនតំណាង២៥៣គ្រួសារ ទាំងចេញពី៦៤ភូមិ ១៨ឃុំ ៧ស្រុក និង៣ខេត្ត។ ការពិគ្រោះយោបល់ជាមួយប្រជាជន បានប្រើប្រាស់កម្រងសំនួរដើម្បីសាកសួរប្រជាជនដោយកំណត់យកប្រជាជន

តំណាងចេញពីខេត្តទាំង៣។ មន្ទីរស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងចំនួនប្រជាជនដែលចូលរួមមានដូចខាងក្រោម៖

តារាង៥.១៖ វិធីសាស្ត្រក្នុងការពិគ្រោះយោបល់ជាសាធារណៈនៅសាលាខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ

ការប្រឹក្សាពិគ្រោះយោបល់			
វិធីសាស្ត្រ	ពេលវេលា	ឈ្មោះអ្នកចូលរួម	តួនាទី
ស្នើសុំពិគ្រោះយោបល់ នៅសាលាខេត្ត ព្រះសីហនុ	២៣ មិថុនា ២០១៥ ម៉ោង ៨:៣០-១១:០០ព្រឹក	ឯកឧត្តម ហេង សំអាន	អភិបាលរងខេត្តព្រះសីហនុ
		លោក ង៉ាន ដារ៉ា	ប្រធានការិយាល័យបូកសរុប
		លោក ជួន សុជាតិ	អនុប្រធានអគ្គិសនី
		អ្នកស្រី ឈុន ដាវី	អភិបាលរងស្រុកស្ទឹងហាវ
		លោក តាន់ ទីន	តំណាងក្រុមហ៊ុន Alex Corporation
		លោក នៅ ធុន	ប្រធានការិយាល័យ EIA នៃមន្ទីរបរិស្ថាន
		លោក សៅ បុរីវឌ្ឍនៈ	អភិបាលស្រុកកំពង់សាលា
		លោក ប្ញូ ចាន់ណា	អនុប្រធានការិយាល័យច្បាប់សាលាខេត្ត
		អ្នកស្រី ភី ណៃគីម	បុគ្គលិកក្រុមហ៊ុន Creative Green Design
		កញ្ញា ទូស សោភ័ណ	នាយករងក្រុមហ៊ុន Creative Green Design
		លោកស្រី សៅ សុវត្ថារី	តំណាងក្រុមហ៊ុន Creative Green Design
កិច្ចប្រជុំពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ	០៣ កក្កដា ២០១៥ ម៉ោង ៨:៣០-១១:០០ព្រឹក	លោក វ៉ី សំណាង	អភិបាលរងខេត្តកំពង់ស្ពឺ
		លោក តាន់ ទីន	ប្រធានគម្រោង Alex Corporation
		លោក ចែម ភីនទីមរទ្ធី	អភិបាលរងស្រុកគងពិសី
		លោក ញ៉េន មន្នីរតនៈ	នាយករដ្ឋបាលស្រុកសំរោងទង
		លោក ឆុយ សូនីន	អនុប្រធានមន្ទីរបរិស្ថាន
		លោក ហេង គួន	ប្រធានមន្ទីរបរិស្ថាន
		លោក ដា រ័ត្ន	នាយកឧទ្យានជាតិគីរីរម្យ
		លោក សុខ ចំរើន	មន្ត្រីពន្ធដាខេត្តកំពង់ស្ពឺ
		លោក ពុត សុភ័ក	ប្រធានអគ្គិសនីខេត្ត

Draft

		លោក ស៊ូន សារ៉ុន	អភិបាលរងស្រុកភ្នំស្រួច
		អ្នកស្រី ភី ណៃគឹម	បុគ្គលិកក្រុមហ៊ុន Creative Green Design
		លោកស្រី សៅ សុវត្ថារី	បុគ្គលិកក្រុមហ៊ុន Creative Green Design
		លោក ប៊ិន សំបាន	អនុប្រធានការិយាល័យរដ្ឋបាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម
		លោក សូស សុផល	អនុប្រធានមន្ទីរបរិស្ថានខេត្ត
		កញ្ញា ទូស សោភ័ណ	នាយករង Creative Green Design
		លោក វ៉ាត វិសាល	បុគ្គលិកក្រុមហ៊ុន Creative Green Design

៥.៤ ការពិគ្រោះយោបល់ នៅសាលាខេត្តព្រះសីហនុ

ការពិគ្រោះយោបល់ ត្រូវបានធ្វើឡើងដោយការប្រជុំពិភាក្សា ដែលមានការចូលរួមពីសាលាខេត្តព្រះសីហនុ អាជ្ញាធរមូលដ្ឋាន មន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធជាច្រើន។ ការប្រជុំនេះត្រូវបានធ្វើនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោង០៨:៣០នាទីព្រឹក នៅសាលាព្រះសីហនុក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហេង សំអាន** អភិបាលរងខេត្តព្រះសីហនុ និងមាន **កញ្ញា ទូស សោភ័ណ** នាយករងក្រុមហ៊ុន **គ្រី អេធីវ ហ្គ្រីន ឌីហ្សាញ** ជាអ្នកធ្វើបទបង្ហាញស្តីពីផែនការចុះសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនៃគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលនេះ។ ការប្រជុំពិភាក្សានេះមានមតិយោបល់ និងអនុសាសន៍ដូចមានរៀបរាប់ខាងក្រោម៖



រូបភាព៥.១៖ កិច្ចប្រជុំពិគ្រោះយោបល់ក្រោមអធីបតីភាព ឯកឧត្តម ហេង សំអាត

Draft

៥.៤.១ ការបញ្ចេញមតិយោបល់របស់អភិបាលរងខេត្តព្រះសីហនុ

ឯកឧត្តម ហេង សំអាន អភិបាលរងខេត្តព្រះសីហនុ ដែលជាគណៈអតិបតីនៃការប្រជុំពិភាក្សានេះ បានមានប្រសាសន៍ និងមតិចូលរួមដូចខាងក្រោម៖

- ជាកិច្ចចាប់ផ្តើមក្នុងនាមខ្ញុំតំណាងអាជ្ញាធរដែនដី សូមសំដែងនូវការគាំទ្រ និងត្រៀមខ្លួនសហការជានិច្ចចំពោះគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល មានទីតាំងពីអនុស្ថានីយ៍អគ្គិសនីស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញ។
- ដើម្បីឱ្យគម្រោងមានការដំណើរការដោយរលូន ខ្ញុំសូមឱ្យលោកដែលជាអភិបាលរងស្រុកត្រូវត្រៀមក្នុងការរួមសហការ ជាមួយក្រុមហ៊ុនទីប្រឹក្សាដែលជាអ្នកបច្ចេកទេស ក្នុងការសិក្សា និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់ជៀសវាងចំពោះបញ្ហាដែលអាចកើតមានឡើងនៅថ្ងៃក្រោយ។ ជាឧទាហរណ៍ករណីក្រុមហ៊ុន មួយចំនួនបានធ្វើការអភិវឌ្ឍដោយមិនបានធ្វើការសិក្សាវាយតម្លៃជាមុន ដែលជាហេតុធ្វើឱ្យកើតមានទំនាស់ពិបាកដោះស្រាយ។
- ពីមុនខេត្តមិនទាន់មានគណៈគម្មាការវាយតម្លៃហេតុប៉ះពាល់នៅឡើយ តែពីពេលនេះ សូមឱ្យមានការដាក់ និងបង្កើតក្រុមជំនាញ និងក្រុមបច្ចេកទេសចម្រុះមួយសម្រាប់ការងារ នេះដោះស្រាយលើបញ្ហាដីប៉ះពាល់តាមគន្លងខ្សែបញ្ជូននេះ។
- សូមឱ្យអង្គសិក្ខាសាលាទាំងមូល មានការបញ្ចេញមតិ និងយោបល់ រាល់បទពិសោធន៍ និងនិតិវិធីក្នុងការអនុវត្តការងារដែលពាក់ព័ន្ធពីមុន ដើម្បីធ្វើយ៉ាងណាធានាឱ្យមានការអនុវត្តគម្រោងនេះដោយរលូន។
- ជាសរុបនៃការពិភាក្សា និងការផ្លាស់ប្តូរយោបល់ថ្ងៃនេះ ហាក់ដូចជាបានល្អ និងក្បោះក្បាយដែលអាចទទួលយកបាន និងអ្វីដែលជាមតិរបស់លោក លោកស្រីទាំងអស់ ខ្ញុំសូមគាំទ្រ និងសូមឱ្យយកខ្លឹមសារនៃការពិភាក្សាទាំងអស់នេះចូលទៅក្នុងកំណត់ហេតុ។
- ខ្ញុំគិតថាការធ្វើបទបង្ហាញអំពីផលប៉ះពាល់ដែលមានកម្រិតទាបបំផុតនេះនឹងបានដឹង និងលឺដល់ប្រជាជន ព្រោះថារាល់ការអភិវឌ្ឍតែងតែមានផលប៉ះពាល់ជានិច្ច គ្មានការអភិវឌ្ឍណាមិនមានផលប៉ះពាល់នោះទេ តែក៏សូមឱ្យធ្វើយ៉ាងណាធ្វើឱ្យផលប៉ះពាល់មានកម្រិតទាបបំផុត។
- សូមឱ្យក្រុមហ៊ុនមេត្តាសិក្សា ឱ្យបានលម្អិតពីផលប៉ះពាល់ឱ្យនៅកម្រិតទាបបំផុត បើអាចជៀសបានសូមបញ្ចៀសខ្សែដែលឆ្លងកាត់តំបន់ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ។
- ជាចុងក្រោយខ្ញុំសង្ឃឹម និងជឿជាក់ថាគម្រោងនេះនឹងដំណើរការឆាប់ៗ និងជោគជ័យ និងសូមជូនពរក្រុមហ៊ុនឱ្យមានដំណើរការយ៉ាងល្អ និងសូមឱ្យអស់លោក លោកស្រីដែលបានចូលរួមថ្ងៃនេះឱ្យមានភាពជោគជ័យ និងសុខភាពល្អទាំងអស់គ្នា។



រូបភាព៥.២៖ ឯកឧត្តម ហេង សំអាន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

Draft

៥.៤.២ ការបញ្ចេញមតិយោបល់របស់អភិបាលរងស្រុកស្ទឹងហាវ

លោកស្រី ឈុន ដាវី អភិបាលរងស្រុកស្ទឹងហាវ បានមានមតិយោបល់ជុំវិញបញ្ហានៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនៃគម្រោងធ្វើគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ដែលមានទីតាំងពីអនុស្ថានីយ៍អគ្គិសនី ស្ទឹងហាវនៅអនុស្ថានីយ៍អគ្គិសនីខាងលិចភ្នំពេញមានដូចតទៅ៖

- គម្រោងខ្សែបញ្ជូនអគ្គិសនីនេះ នឹងត្រូវបានសាងសង់ពីអនុស្ថានីយ៍នៅក្នុងភូមិសាស្ត្រស្រុកស្ទឹងហាវដែលទីតាំងអនុស្ថានីយ៍នេះ មានទីតាំងស្ថិតនៅក្នុងភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន CIINDG ដែលជាអគ្គិសនីមានប្រភពពីថាមពលធ្យូងថ្ម។
- តាមការធ្វើបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានបង្ហាញថា គម្រោងខ្សែបញ្ជូននេះនឹងកាត់ភូមិសាស្ត្រស្រុកនាងខ្ញុំចំនួន៣ឃុំ ដែលឃុំទាំងនេះបានកំណត់ប្លង់ប្រើប្រាស់ដីធ្លីរួចរាល់ហើយ ដែលជាទិន្នន័យដែលមានស្រាប់សម្រាប់ជំនួយដល់ការសិក្សាវាយតម្លៃលើ ការប៉ះពាល់ដីធ្លីផងដែរ។
- មួយវិញទៀតគម្រោងខ្សែបញ្ជូនអគ្គិសនីនេះប្រហែលជាឆ្លងកាត់ផ្លូវដែក(ផ្លូវរទេះភ្លើង) ហេតុដូចនេះការសាងសង់ខ្សែបញ្ជូនអគ្គិសនី ក្រុមហ៊ុនត្រូវគិតគូរថាតើត្រូវទុកគម្លាតប៉ុន្មាន ម៉ែត្រពីបង្គោលអ័ក្ស មកផ្លូវរទេះភ្លើង។

- ជាចុងក្រោយក្នុងនាមខ្ញុំតំណាងឱ្យស្រុកស្ទឹងហាវ ស្នើសុំដល់ក្រុមហ៊ុនសាងសង់ Alex Corporation ត្រូវសិក្សាផ្ទៃដីប៉ះពាល់ឱ្យបានច្បាស់ និងធ្វើការដោះស្រាយទូទាត់សងដល់ប្រជាជនដែលរងការប៉ះពាល់ឱ្យបានត្រឹមត្រូវ។ ម៉្យាងទៀតស្នើសុំឱ្យមានរៀបចំសិក្ខាសាលាដល់ប្រជាជនដែលនៅក្បែរតំបន់គម្រោងអំពីការប៉ះពាល់នៅពេល ដែលគាត់ទៅប៉ះពាល់បង្គោល។

រូបភាព៥.៣៖ លោកស្រី ឈុន ដារី អភិបាលរងស្រុកស្ទឹងហាវ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

Draft

៥.៤.៣ ការបញ្ចេញមតិយោបល់របស់អនុប្រធានអគ្គិសនីខេត្តព្រះសីហនុ

លោក ជួន សុជាតិ អនុប្រធានអគ្គិសនីខេត្តព្រះសីហនុ បានមានមតិយោបល់ ជុំវិញបញ្ហាលើការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅសាលាខេត្តព្រះសីហនុកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ មានដូចតទៅ៖

- ខ្ញុំសូមធ្វើការគាំទ្រចំពោះ ការសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ទាំងស្រុង ព្រោះគម្រោងនេះអាចជួយក្នុងការអភិវឌ្ឍប្រទេសជាតិ ព្រោះបច្ចុប្បន្នការផ្គត់ផ្គង់អគ្គិសនីមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ។
- បញ្ហានៃការប៉ះពាល់ដល់ផ្ទះសម្បែង បរិស្ថាន និងដើមឈើ នៅតាមគន្លងខ្សែបញ្ជូននេះគឺក្រុមហ៊ុនបានធ្វើការទូទាត់សំណងជូនដល់ប្រជាជនដែលរងការប៉ះពាល់។ ចំពោះដើមឈើដែលមានកម្ពស់ខ្ពស់ត្រូវបានបង្វែរឱ្យប្រជាជនផ្លាស់ប្តូរនូវប្រភេទដំណាំវិញ ដោយដាំនូវ

ដំណាំដែលមានកម្ពស់ទាបៗ។ ចំពោះបញ្ហាផ្ទះសម្បែងគឺមិនអនុញ្ញាតឱ្យមានសំណង់នៅចន្លោះ២០ម៉ែត្រទៅ៣០ម៉ែត្រសងខាងទេ។

- ចំពោះបទពិសោធន៍គន្លងមក ការដោះស្រាយទូទាត់សងនូវផលប៉ះពាល់ និងហាមឃាត់មិនឱ្យមានសំណង់នៅចន្លោះហាមឃាត់ទាំងនោះ បានតែ១ឆ្នាំទៅ២ឆ្នាំទេ ក្រោយមកប្រជាជននៅតែមកតាំងលំនៅនៅក្បែរបង្គោលដដែល ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការគ្រប់គ្រងរាល់បញ្ហាដែលកើតមានទាំងនេះ។
- សូមបញ្ជាក់ដែរថារាល់គម្រោងខ្សែបញ្ជូនអគ្គិសនីទាំងអស់ មុននឹងសាងសង់ត្រូវបានសិក្សានិងគូសវាស បញ្ចៀសរាល់ការប៉ះពាល់ផ្ទះសម្បែង ប្រជាជន គេចវៀងពីតំបន់ទីប្រជុំជន ដើម្បីបញ្ចៀសរាល់ការប៉ះពាល់ជាមួយប្រជាជន ឱ្យដល់កម្រិតទាបបំផុត។
- ជាចុងក្រោយ ខ្ញុំបាទតំណាងឱ្យអគ្គិសនីខេត្តព្រះសីហនុ ត្រៀមខ្លួនសហការជាមួយក្រុមហ៊ុនជានិច្ច។

រូបភាព៥.៩៖ លោក ជូន សុជាតិ អនុប្រធានអគ្គីសនីខេត្ត ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៨.៤ ការបញ្ចេញមតិយោបល់របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តព្រះសីហនុ

លោកហ៊ុន ធីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តព្រះសីហនុ បានមានមតិយោបល់ជុំវិញបញ្ហានៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងលើគម្រោងធ្វើ ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex

Corporation ក្នុងកិច្ចប្រជុំនៅសាលាខេត្តព្រះសីហនុកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥មានដូចតទៅ៖

- ក្នុងការធ្វើបទបង្ហាញឃើញមានបង្ហាញតែចន្លោះសុវត្ថិភាព សម្រាប់កំណត់កម្ពស់ដើមឈើ តែមិនទាន់បានឃើញក្រុមហ៊ុនបង្ហាញពីចន្លោះសុវត្ថិភាព ក្នុងការកំណត់រយៈចម្ងាយចំពោះលំនៅដ្ឋានប្រជាជន។ ហេតុដូចនេះ ក្នុងរបាយការណ៍សូមបំពេញបន្ថែមនូវចំនុចនេះ។
- ចំពោះលក្ខណៈបច្ចេកទេសនៃការសាងសង់បង្គោល សូមឱ្យមានការគិតគូរទៅលើការធ្លាក់ឃាររបស់ខ្សែផ្គររន្ទះផង។
- ចំពោះការប៉ះពាល់ទៅលើទ្រព្យសម្បត្តិប្រជាជន តើក្រុមហ៊ុនមានគោលការណ៍យ៉ាងណាដើម្បីដោះស្រាយប្រភេទលំនៅដ្ឋានគួរដោះស្រាយយ៉ាងណា? ប្រភេទផ្ទៃដីស្រែចម្ការគួរដោះស្រាយយ៉ាងណា? ប្រភេទផ្ទៃដីភូមិគួរដោះស្រាយយ៉ាងណា?
- ជាចុងក្រោយខ្ញុំក៏ស្នើសុំក្រុមហ៊ុនសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ដោះស្រាយនូវការប៉ះពាល់ទាំងឡាយដោយសន្តិវិធី និងទៅតាមតម្លៃទីផ្សារដើម្បីជៀសវាងទំនាស់ទាំងឡាយ។

Draft

រូបភាព៥.៥៖ លោកហ៊ុន ធីតំណាងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៤.៥ ការបញ្ចេញមតិយោបល់របស់អភិបាលស្រុកកំពង់សិលា

លោក សៅ បុរីវឌ្ឍនៈ អភិបាលស្រុកកំពង់សិលា បានមានមតិយោបល់ជុំវិញបញ្ហានៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោង ធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅសាលាខេត្តព្រះសីហនុកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកអភិបាលបានមានមតិ និងយោបល់ទាក់ទងទៅនឹង ការអូសខ្សែបណ្ដាញអគ្គិសនី ប៉ះប្រជាជន បើអាចសូមឱ្យគេច ឬវៀងពីតំបន់ដែលមានប្រជាជនច្រើន ឬតំបន់ទីប្រជុំជន ក្នុងគោលបំណងដើម្បីបង្រួមផលប៉ះពាល់ខ្លាំង។
- សូមឱ្យការដោះស្រាយរាល់បញ្ហាផលប៉ះពាល់ទាំងអស់ ដោយអាចទទួលយកបានទាំងសងខាង និងមានតម្លាភាព រវាងក្រុមហ៊ុន និងប្រជាជន។
- ក្នុងនាមជាអាជ្ញាធរ និងប្រជាជនទាំងអស់សូមសំដែងនូវការគាំទ្រ និងត្រៀមខ្លួនដើម្បីសហការយ៉ាងជិតស្និតជាមួយគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។ ម៉្យាងវិញទៀតក៏ស្នើសូមឱ្យក្រុមហ៊ុនត្រូវគោរពតាមលក្ខន្តិកៈ និងច្បាប់ដែលពាក់ព័ន្ធទាំងឡាយក្នុងការអភិវឌ្ឍ ឬសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ។

Draft

រូបភាព៥.៦៖ លោក សៅ បុរីវឌ្ឍនៈ អភិបាលស្រុកកំពង់សិលាក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៤.៦ ការបញ្ចេញមតិយោបល់របស់លោកប្រធានការិយាល័យ EIA នៃមន្ទីរបរិស្ថានខេត្ត

លោក នៅ ឆុន ប្រធានការិយាល័យ EIAនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុបានមានមតិយោបល់ជុំវិញបញ្ហានៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល របស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅសាលាខេត្តព្រះសីហនុ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥មានដូចតទៅ៖

- លោកបានមានជាមតិយោបល់ទាក់ទង និងបច្ចេកទេសនៃការគ្រប់គ្រងសំណល់ពីគម្រោង លោកយល់ឃើញថារាល់ការអភិវឌ្ឍទាំងអស់តែងតែបន្សល់ទុកនូវការសំណល់ផ្សេងៗ ពីគម្រោងសាងសង់។ ដូចច្នេះសូមឱ្យក្រុមហ៊ុនមេត្តាយកចិត្តទុកដាក់ឱ្យបានជិតដល់ចំពោះការគ្រប់គ្រង និងធ្វើយ៉ាងណាកាត់បន្ថយការបញ្ចេញ កាកសំណល់ ដែលនាំឱ្យមានផលប៉ះពាល់ ដល់បរិស្ថាន។
- លោកបានបន្តទៀតថា ហើយបើមានការប៉ះពាល់ទាំងឡាយណាជាមួយប្រជាជន សូមឱ្យការដោះស្រាយ និងការទូរទាត់សំណងចំពោះផលប៉ះពាល់ពីគម្រោងនេះធ្វើការ ចរចា និងដោះស្រាយឱ្យមានតម្លាភាព និងភាពត្រឹមត្រូវ ។
- ហើយយើងខ្ញុំសូមសំដែងការគាំទ្រ និងសហការជាមួយក្រុមហ៊ុនយ៉ាងជិតស្និតដើម្បីរួមគ្នាអភិវឌ្ឍន៍ជាតិយើង និងដើម្បីប្រជាជនមានអគ្គិសនី ក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យ។

រូបភាព៥.៧៖ លោក នៅ ឆុន ប្រធានការិយាល័យ EIA នៃមន្ទីរបរិស្ថានខេត្ត

៥.៤.៧ ការបញ្ចេញមតិយោបល់របស់តំណាងក្រុមហ៊ុន Alex Corperative

លោក តាន់ ទីន តំណាងក្រុមហ៊ុន Alex Corporation បានមានមតិយោបល់ជុំវិញបញ្ហានៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងលើគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល របស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅសាលាខេត្តព្រះសីហនុ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកជាតំណាងក្រុមហ៊ុន Alex Corporation បានធ្វើការរំលឹកឡើងវិញត្រួសៗ ពីគម្រោងនេះ។ គម្រោងនេះជាគម្រោងដែលត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាលព្រោះគម្រោងខ្សែបញ្ជូនអគ្គិសនីភាគច្រើនជាគម្រោងវិយោគពីក្រៅប្រទេស ទើបតែគម្រោងនេះទេដែលជាវិនិយោគគិនក្នុងស្រុក។ ដើម្បីកាត់បន្ថយ និងជៀសវៀងនៅផលប៉ះពាល់ទាំងឡាយក្រុមហ៊ុនបានសហការជាមួយក្រុមហ៊ុនប្រឹក្សាយោបល់ឯករាជ ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុន។
- ឬងផលប៉ះពាល់ដល់អាគារ សំណង់ សំណាងផ្សេងៗ គឺមានក្រុមហ៊ុនឯករាជដែលមានជំនាញហើយគេនឹងសិក្សាពីការប៉ះពាល់ទៅលើសង្គមដូចជាផ្ទះប្រជាជន ដីស្រែ ចម្ការ គេនឹងធ្វើទិន្នន័យដល់ក្រុមហ៊ុន។ ក្រុមហ៊ុនទីប្រឹក្សាឯករាជនេះ គាត់ក៏មិនលម្អៀងទៅ ប្រជាជន ឬក៏ក្រុមហ៊ុនដែរ។
- ឆ្លៀតឱកាសនេះខ្ញុំសូមអគុណដល់អាជ្ញាធរមូលដ្ឋាន លោកឯកឧត្តម លោកអាជ្ញាធរខាងអគ្គិសនី ដែលបានគាំទ្រដល់គម្រោងនេះយ៉ាងពេញទំហឹងហើយក្រុមហ៊ុនពិតជាមានការសប្បាយរីករាយដោយមានការចូលរួមសហការ។ ហើយឆ្លៀតក្នុងឱកាសនេះក៏សំណូមពរដល់ឯកឧត្តមមេត្តាប្រាប់ដល់ប្រជាជនឱ្យបានដឹងថានេះជាក្រុមហ៊ុនឯកជន ដូចនេះនៅពេលមានផលប៉ះពាល់គាត់ទាយកចំណេញបានច្រើន តាមពិតគោលការណ៍ក្រុមហ៊ុនគឺត្រូវតែដោះស្រាយជូនប៉ុន្តែមានក្រុមហ៊ុនឯករាជមួយគេធ្វើការវាយតម្លៃ តើត្រូវដោះស្រាយយ៉ាងណា ឬក៏តំបន់នោះមិនត្រូវដោះស្រាយ ឬក៏ត្រូវដោះស្រាយហើយតម្លៃគិតយ៉ាងមិច។ អញ្ចឹងខ្ញុំសូមឱ្យឯកឧត្តមដែលជាតំណាងប្រជាជនប្រជាជនជួយមេត្តាពន្យល់ ដល់ប្រជាជនឱ្យយល់ច្បាស់ថា ហេតុអ្វីបានជាក្រុមហ៊ុននេះជាក្រុមហ៊ុនឯកជន។ តាមពិតគេហៅថាគម្រោង BOT (Build Operate Transfer) ក្រោយពីយើងបានរួចដើម និងចំណេញខ្លះវានឹងក្លាយជារបស់រដ្ឋ។ អញ្ចឹងវាមិនមែនជារបស់ក្រុមហ៊ុនរហូតនោះទេ យើងគ្រាន់តែមានចំណេញត្រង់ថារដ្ឋាភិបាលត្រូវការទុនសម្រាប់ការវិនិយោគអញ្ចឹង យើងក៏បើកដៃឱ្យក្រុមហ៊ុនបរទេសគេមកវិនិយោគហើយនៅពេលចំនេញគេយកទៅស្រុកគេវិញហើយ។ អញ្ចឹងរាជរដ្ឋាភិបាលបានជម្រុញលើកទឹកចិត្ត គម្រោងនេះជាគម្រោងទីមួយហើយដែលធំជាងគេដែលវិនិយោគធំជាងគេនៅលើវិស័យថាមពលនឹងឱ្យមកវិនិយោគក្នុងស្រុក។

- គោលបំណងនៃការអនុវត្តគម្រោងគឺដើម្បីផ្តល់ថាមពល ដែលភ្ជាប់ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅផ្គត់ផ្គង់អគ្គិសនីជូនប្រជាជនដែលរស់នៅរាជធានីភ្នំពេញ និងខាងលិចភ្នំពេញ។ ហេតុអ្វីបានជាក្រុមហ៊ុនយើងត្រូវការវិនិយោគទៅលើខ្សែបញ្ជូនមួយទៀត ដោយសារបណ្តាញចាស់ដែលមានស្រាប់ដែលឆ្លងកាត់កំពត ទៅតាកែវវាមិនអាចបញ្ជូនថាមពលដែលចេញពីរោងចក្រធ្យូងថ្មអស់ទេ ហេតុដូចនេះខ្សែថ្មីយើងអាចបញ្ជូនបានរហូតទៅដល់ជាង ១.០០០ គីឡូវ៉ាត់ជាកម្លាំងបញ្ជូន ចំណែកឯ២៣០គីឡូវ៉ុលជាកម្រិតតង់ស្យុង។ នៅពេលដែលយើងបង្កើតតង់ស្យុងខ្ពស់ ដើម្បីឱ្យខ្សែធ្លាក់មកតូចងាយស្រួលនឹងធ្វើបណ្តាញជាគោលបំណងរួម។ ហេតុដូច្នេះខ្ញុំសូមឱ្យអាជ្ញាធរមូលដ្ឋាន សូមមេត្តាជួយសហការចូលរួមណែនាំប្រជាជនឱ្យយល់ពីគោលបំណងនៃការអភិវឌ្ឍនេះ។
- គាត់បានតបទៀតថាការអភិវឌ្ឍ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗខាងមុខនេះពីព្រោះនៅក្នុងឆ្នាំ ២០១៧ យើងត្រូវបញ្ចប់គម្រោង ពីព្រោះថាមពលធ្យូងថ្មបានចេញហើយប៉ុន្តែយើងខ្វះខ្សែបញ្ជូនថាមពលទៅភ្នំពេញ។ ហេតុចដូចនេះ ទាមទារឱ្យមានការលឿនបំផុតពីព្រោះខាងមុខនេះនឹងមានក្រុមហ៊ុនផ្នែកពិគ្រោះយោបល់ខាងដោះស្រាយផលប៉ះពាល់ និងបង្កើតគណៈកម្មការដែលមានការគាំទ្រពីខាងអគ្គិសនីកម្ពុជា និងក្រសួងពាក់ព័ន្ធចុះមកចូលរួមជាមួយអាជ្ញាធរ គ្រប់លំដាប់ថ្នាក់មានខេត្ត ស្រុក និងឃុំ។
- ដោយសារការសិក្សាផលប៉ះពាល់មានការលំបាក និងស្មុកស្មាញបំផុត និងចំណាយទុនច្រើន ដូចនេះយើងត្រូវពឹងពាក់ទៅលើក្រុមប្រឹក្សាយោបល់ដែលគេមានជំនាញច្បាស់លាស់សិក្សាដោះស្រាយគម្រោងជាច្រើនឱ្យគេធ្វើ។ ដូចនេះខ្ញុំមិនទាន់ដឹងប្រាកដថាខ្សែបញ្ជូនអគ្គិសនីរបស់ក្រុមហ៊ុនប៉ះពាល់កន្លែងណានៅឡើយទេ ហើយតំបន់ណាចាត់ចូលជាតំបន់ឧស្សាហកម្ម តំបន់ណាជាតំបន់កសិកម្ម និងតំបន់ណាជាជម្រករបស់ប្រជាជននៅឡើយទេ។ របាយការណ៍នេះនឹងទទួលបានឆាប់ៗនៅពេលក្រុមហ៊ុនទីប្រឹក្សាឯករាជបញ្ចប់នូវការសិក្សារបស់គាត់។
- ជាចុងក្រោយខ្ញុំតំណាងឱ្យក្រុមហ៊ុន Alex Coporation សូមថ្លែងអំណរគុណដល់អភិបាលរងខេត្តព្រះសីហនុ លោក លោកស្រីគ្រប់ជំនាញពាក់ព័ន្ធ និងអាជ្ញាធរទាំងអស់ដែលបានគាំទ្រចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ក្រុមហ៊ុននឹងចូលរួមសហការជានិច្ច និងគ្រប់ការលៈទេសៈនៅដំណាក់កាលសាងសង់ និងអនុវត្តគម្រោង។

Draft



រូបភាព៥.៨៖ លោក តាន់ ទីន តំណាងក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

Draft

៥.៥ សង្ខេបលទ្ធផលនៃការប្រជុំពិភាក្សាពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុដែលមាន **ឯកឧត្តម ហេង សំអាន** អភិបាលរងខេត្តព្រះសីហនុជាគណៈអធិបតី និងមានក្រុមហ៊ុនទីប្រឹក្សា គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ ជាអ្នកធ្វើបទបង្ហាញ ព្រមទាំងមានមន្ទីរ និងស្ថាប័នដែលពាក់ជាច្រើនបានមកផ្តល់យោបល់ និងអនុសាសន៍ផ្សេងៗដែលទាក់ទងនឹងគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានបង្ហាញឱ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយប៉ុន្តែក៏នៅមានចំនុចមួយចំនួនត្រូវបំពេញបន្ថែមដូចខាងក្រោម៖

- ការអូសខ្សែបញ្ជូនអគ្គិសនីនេះ អាចធ្វើឱ្យមានការប៉ះពាល់ដល់ព្រៃឈើ និងសត្វព្រៃក្នុងតំបន់ឧទ្យានជាតិ ហេតុដូចនេះក្រុមហ៊ុនត្រូវសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ ដើម្បីធ្វើសារពើភ័ណ្ឌព្រៃឈើ។
- ត្រូវកំណត់ទីតាំង និងចម្ងាយដែលប្រជាជនអាចសាងសង់លំនៅដ្ឋានបាន និងចម្ងាយរវាងផ្លូវ និងបង្គោលភ្លើងឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការរៀបចំផែនការអភិវឌ្ឍនៅថ្ងៃក្រោយ។

- ចំពោះផែនការបច្ចេកទេសនៃការគ្រប់គ្រងសំណល់ ត្រូវសិក្សាឱ្យបានច្បាស់លាស់ ដើម្បីជៀសវៀងរាល់ការបំពុលនានាទៅលើបរិស្ថាន និងប្រជាជនដែលនៅក្នុង និងក្បែរតំបន់គម្រោង។
- សូមឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ រៀបចំឱ្យមាន Road of line ដើម្បីងាយស្រួលក្នុងការជុសជុលនៅថ្ងៃក្រោយ ហើយរាល់ការកំណត់ទីតាំងបង្គោលអគ្គិសនីសូមឱ្យធ្វើយ៉ាងណា បញ្ចៀសពីតំបន់ដែលមានផលប៉ះពាល់តិចបំផុតពីគម្រោង។
- នៅក្នុងទីតាំងគម្រោងអូសខ្សែបញ្ជូនអគ្គិសនីនេះ នឹងមានការប៉ះពាល់ដល់ដីស្រែចម្ការ ផ្ទះសម្បែងប្រជាជន ហេតុដូចនេះក្រុមហ៊ុនត្រូវមានគោលការណ៍ដោះស្រាយជាមួយប្រជាជនឱ្យបានច្បាស់លាស់ និងសហការជាមួយអាជ្ញាធរ និងមន្ទីរដែលពាក់ព័ន្ធ ដើម្បីកុំឱ្យមានបញ្ហាទៅថ្ងៃក្រោយ។
- ចុងក្រោយអាជ្ញាធរខេត្តព្រះសីហនុ សូមធ្វើការគាំទ្រ និងជួយជម្រុញការអភិវឌ្ឍលើគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីនេះ ឱ្យដំណើរការបានយ៉ាងឆាប់រហ័ស។

Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង ៥.២៖ សេចក្តីសង្ខេបយោបល់ និងសំនូមពរនៃការពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ

ឈ្មោះ	តួនាទី	រូបភាព	គាំទ្រការអភិវឌ្ឍ	មិនគាំទ្រការអភិវឌ្ឍ	មតិយោបល់/អនុសាសន៍
ឯកឧត្តម ហេង សំអាន	អភិបាលរង ខេត្តព្រះសីហនុ		✓		• គាំទ្រ និងត្រៀមខ្លួនសហការជានិច្ចចំពោះគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ។ • និងបង្កើតក្រុមបច្ចេកទេសចម្រុះមួយ សម្រាប់ការដោះស្រាយលើបញ្ហាដីប៉ះពាល់តាមគន្លងខ្សែបញ្ជូននេះ • សូមឱ្យក្រុមហ៊ុនមេត្តាសិក្សា ឱ្យបានលម្អិតពីផលប៉ះពាល់ឱ្យនៅកម្រិតទាបបំផុត បើអាចជៀសបានសូមបញ្ចៀសខ្សែដែលឆ្លងកាត់តំបន់ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ។ • ជាចុងក្រោយសង្ឃឹម និងជឿជាក់ថាគម្រោងនេះនិងដំណើរការឆាប់ៗ និងជោគជ័យ និងសូមជូនពរក្រុមហ៊ុនឱ្យមានដំណើរការយ៉ាងល្អ និងសូមឱ្យអស់លោក លោកស្រីដែលបានចូលរួមថ្ងៃនេះឱ្យមានភាពជោគជ័យ និងសុខភាពល្អទាំងអស់គ្នា។
លោកស្រី ឈុន ដាវី	អភិបាលរង ស្រុកស្ទឹងហាវ		✓		• ទីតាំងអនុស្ថានីយ៍នេះ មានទីតាំងស្ថិតនៅក្នុងភូមិ៤ ឃុំអូត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន CIINDG ដែលជាអគ្គិសនីមានប្រភពពីថាមពលធ្យូងថ្ម។ • គម្រោងខ្សែបញ្ជូននេះ នឹងកាត់ភូមិសាស្ត្រសាស្ត្រស្រុកនាងខ្ញុំចំនួន៣ឃុំ ដែលឃុំទាំងនេះបានកំណត់ប្លង់ប្រើប្រាស់ដីរួចរាល់ហើយដែលជាទិន្នន័យដែលមានស្រាប់ សម្រាប់ជំនួយដល់ការសិក្សាវាយតម្លៃលើការប៉ះពាល់ដីធ្លីផងដែរ។

						• ការសាងសង់ខ្សែបញ្ជូនអគ្គិសនី ក្រុមហ៊ុនត្រូវគិតគូរថាតើត្រូវទុកគម្លាតប៉ុន្មានម៉ែត្រ ពីបង្គោលអ័ក្សមកផ្លូវរទេះភ្លើង។ • ស្នើសុំដល់ក្រុមហ៊ុនសាងសង់ Alex Corporation ត្រូវសិក្សាផ្ទៃដីប៉ះពាល់ឱ្យបានច្បាស់ និងធ្វើការដោះស្រាយទូទាត់សងដល់ប្រជាជនដែលរងការប៉ះពាល់ឱ្យបានត្រឹមត្រូវ។ • ស្នើសុំឱ្យមានរៀបចំសិក្ខាសាលា ដល់ប្រជាជនដែលនៅក្បែរតំបន់គម្រោងអំពីការប៉ះពាល់នៅពេល ដែលគាត់ទៅប៉ះពាល់បង្គោល។
៣	លោក ជួន សុជាតិ	អនុប្រធាន អគ្គិសនីខេត្ត ព្រះសីហនុ		✓		• គាំទ្រចំពោះការសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ទាំងស្រុង ព្រោះជួយក្នុងការអភិវឌ្ឍប្រទេសជាតិ ព្រោះបច្ចុប្បន្នការផ្គត់ផ្គង់អគ្គិសនីមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅឡើយ។ • ការទូទាត់សំណងជូនដល់ប្រជាជនដែលរងការប៉ះពាល់ ចំពោះដើមឈើដែលមានកម្ពស់ ខ្ពស់ត្រូវបានបង្វែផ្លាស់ប្តូរប្រភេទដំណាំវិញ ដោយដាំនូវដំណាំដែលមានកម្ពស់ទាបៗ។ បញ្ហាផ្ទះសម្បែងគឺមិនអនុញ្ញាតឱ្យមានសំណង់នៅចន្លោះ២០ម៉ែត្រទៅ៣០ម៉ែត្រសងខាងទេ។ • បញ្ហាដែលលំបាកដោះស្រាយគឺបន្ទាប់ពីការដោះស្រាយហើយ មានប្រជាជនមកតាំងលំនៅវិញ។ • គម្រោងខ្សែបញ្ជូនអគ្គិសនីទាំងអស់ ព្យាយាមបញ្ចៀសរាល់ការប៉ះពាល់ផ្ទះសម្បែង ប្រជាជនគេចវៀងពីតំបន់ទីប្រជុំជន។ • ជាចុងក្រោយ ខ្ញុំបាទតំណាងឱ្យអគ្គិសនីខេត្តព្រះសីហនុ ត្រៀមខ្លួនសហការជាមួយក្រុមហ៊ុនជានិច្ច។

[illegible], Sk.Tuol Kork 11a, Khan Russey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៨	លោក ហ៊ុន ធី	ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់		✓		• បន្ថែមចន្លោះសុវត្ថិភាព ក្នុងការកំណត់រយៈចម្ងាយចំពោះលំនៅដ្ឋានប្រជាជនប្រជាជន។ • ចំពោះលក្ខណៈបច្ចេកទេសនៃការសាងសង់បង្គោល សូមឱ្យមានការគិតគូរទៅលើការធ្លាក់យាររបស់ខ្សែផ្គរន្ទះផង។ • ក្រុមហ៊ុនមានគោលការណ៍យ៉ាងណាដើម្បីដោះស្រាយប្រភេទលំនៅដ្ឋានគួរដោះស្រាយយ៉ាងណា? ប្រភេទផ្ទៃដីស្រែចម្ការគួរដោះស្រាយយ៉ាងណា? ប្រភេទផ្ទៃដីភូមិគួរដោះស្រាយយ៉ាងណា? • ជាចុងក្រោយខ្ញុំក៏ស្នើសុំក្រុមហ៊ុន ដោះស្រាយនូវការប៉ះពាល់ទាំងឡាយដោយសន្តិវិធី និងទៅតាមតម្លៃទីផ្សារដើម្បីជៀសវាងទំនាស់ទាំងឡាយ។
	លោក សៅ បុរីវឌ្ឍនៈ	អភិបាលស្រុកកំពង់សាលា		✓		• ការអូសខ្សែបណ្តាញអគ្គិសនីប៉ះប្រជាជន បើអាចសូមឱ្យគេចឬវៀងពីតំបន់ដែលមានប្រជាជនច្រើន ឬតំបន់ទីប្រជុំជន • សូមឱ្យការដោះស្រាយរាល់បញ្ហាផលប៉ះពាល់ទាំងអស់ ដោយអាចទទួលយកបានទាំងសងខាង និងមានតម្លាភាពរវៀងក្រុមហ៊ុន និងប្រជាជនប្រជាជន។ • គាំទ្រ និងត្រៀមខ្លួនដើម្បីសហការយ៉ាងជិតស្និតជាមួយក្រុមហ៊ុន • ម្យ៉ាងវិញទៀតក៏ស្នើសូមឱ្យ ក្រុមហ៊ុន ត្រូវគោរពតាមលក្ខន្តិកៈ និងច្បាប់ដែលពាក់ព័ន្ធទាំងឡាយ ក្នុងការអភិវឌ្ឍ
	លោក នៅ ឆុន	ប្រធានការិយាល័យ		✓		• សូមឱ្យក្រុមហ៊ុនមេត្តាយកចិត្តទុកដាក់ឱ្យបានជិតដល់ចំពោះការគ្រប់គ្រង និងធ្វើយ៉ាងណាកាត់បន្ថយការបញ្ចេញកាក

		EIA នៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ				សំណល់ • ការប៉ះពាល់ទាំងឡាយណាជាមួយប្រជាជនប្រជាជន សូមឱ្យការដោះស្រាយ និងការទូទាត់សំណងចំពោះផលប៉ះពាល់ពីគម្រោងនេះ ធ្វើការចរចា និងដោះស្រាយឱ្យមានតម្លាភាព និងភាពត្រឹមត្រូវ ។ • ហើយយើងខ្ញុំសូមសំដែងការគាំទ្រ និងសហការជាមួយក្រុមហ៊ុនយ៉ាងជិតស្និត ដើម្បីរួមគ្នាអភិវឌ្ឍន៍ជាតិយើង។
៧	លោក គាន់ ទីន	តំណាងក្រុមហ៊ុន Alex Corporation				• គម្រោងនេះជាគម្រោងដែលត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាល។ ដើម្បីកាត់បន្ថយ និងជៀសវៀងនៅផលប៉ះពាល់ទាំងឡាយ ក្រុមហ៊ុនបានសហការជាមួយក្រុមហ៊ុនប្រឹក្សាយោបល់ឯករាជ ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុន។ • រីឯផលប៉ះពាល់ដល់ អាគារ សំណង់ សំណងផ្សេងៗ គឺមានក្រុមហ៊ុនឯករាជដែលមានជំនាញ ហើយគេនឹងសិក្សា • សូមអគុណដល់អាជ្ញាធរមូលដ្ឋាន លោកឯកឧត្តម លោកអាជ្ញាធរខាងអគ្គិសនី ដែលបានគាំទ្រដល់គម្រោងនេះយ៉ាងពេញទំហឹង ហើយក្រុមហ៊ុនពិតជាមានការសប្បាយរីករាយ ដោយមានការចូលរួមសហការ។ • ការអភិវឌ្ឍនឹងចាប់ផ្តើមក្នុងពេលឆាប់ៗខាងមុខនេះ ពីព្រោះនៅក្នុងឆ្នាំ២០១៧ យើងត្រូវបញ្ចប់គម្រោង ពីព្រោះថាមពលធ្យូងថ្មបានចេញហើយ ប៉ុន្តែយើងខ្វះខ្សែបញ្ជូនថាមពលទៅភ្នំពេញ។

Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

					• ក្រុមហ៊ុន Alex Coporation សូមថ្លែងអំណរគុណដល់អភិបាលរងខេត្តព្រះសីហនុ លោក លោកស្រីគ្រប់ជំនាញពាក់ព័ន្ធ និងអាជ្ញាធរទាំងអស់ដែលបានគាំទ្រចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះក្រុមហ៊ុននឹងចូលរួមសហការជានិច្ច និងគ្រប់កាលៈទេសៈនៅដំណាក់កាលសាងសង់ និងអនុវត្តគម្រោង។

Draft

៥.៦ ការពិគ្រោះយោបល់ដំណាក់កាលដំបូងនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ

ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងដោយការប្រជុំពិភាក្សា ដែលមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន មន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធជាច្រើន។ ការប្រជុំនេះត្រូវបានធ្វើនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១៥ វេលាម៉ោង០៨:៣០នាទីព្រឹក នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម វ៉ី សំណាង** អភិបាលរងខេត្តព្រះកំពង់ស្ពឺ និងមាន **កញ្ញា ទូស សោភ័ណ** នាយករងក្រុមហ៊ុន **គ្រី អេធីវ ហ្គ្រីន ឌីហ្សាញ** ជាអ្នកធ្វើបទបង្ហាញស្តីពីលទ្ធផល នៃរបាយការណ៍សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនៃគម្រោងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលនេះ ។ ការប្រជុំពិភាក្សានេះមានមតិយោបល់ និងអនុសាសន៍ដូចមានរៀបរាប់ខាងក្រោម៖

Draft

រូបភាព៥.៩៖ កិច្ចប្រជុំពិគ្រោះយោបល់ដំបូង ក្រោមអធីបតីភាព ឯកឧត្តម វ៉ី សំណាង

៥.៦.១ ការបញ្ចេញមតិយោបល់អភិបាលរងខេត្តកំពង់ស្ពឺ

ឯកឧត្តម វ៉ី សំណាង អភិបាលរងខេត្តកំពង់ស្ពឺ ដែលជាគណៈអតិបតីនៃការប្រជុំពិភាក្សានេះបានមានប្រសាសន៍ និងមតិចូលរួមដូចខាងក្រោម៖

- ឯកឧត្តមបានមានមតិចាប់ផ្តើមថា ក្នុងនាមខ្ញុំតំណាងអាជ្ញាធរដែនដី សូមសំដែងនូវការគាំទ្រ និងត្រៀមខ្លួនសហការជានិច្ចចំពោះគម្រោងខ្សែបញ្ជូន អគ្គិសនីតង់ស្យុងខ្ពស់នេះ។

- ឯកឧត្តមសូមឱ្យអង្គសិក្ខាសាលាទាំងមូល មានការបញ្ចេញមតិ និងយោបល់រាល់បទពិសោធន៍ និងនិតិវិធីក្នុងការអនុវត្តការងារដែលពាក់ព័ន្ធពីមុនដើម្បីធ្វើ យ៉ាងណាធានាឱ្យមានការអនុវត្តគម្រោងនេះបានល្អ។
- ឯកឧត្តមក៏បានមានជាមតិចូលរួមទាក់ទង និងការកំណត់ UTM ដែលបានកំណត់ដោយក្រុមហ៊ុន ព្រោះថាឃើញមានការសិក្សាអំពីទីតាំងដែលឆ្លងកាត់ពីការអូសខ្សែ និងបង្គោលអគ្គិសនី។
- សូមឱ្យមានវិធានការណាដែលអាចបញ្ចៀសបាននូវរាល់ហានិភ័យដែលអាច និងកើតមាននៅពេលអនាគតព្រោះថាការសិក្សា និងយល់ដឹងនៅតែមានកម្រិត។
- សូមឱ្យមានការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយអំពីផលប៉ះពាល់ពីគម្រោង ទៅដល់ប្រជាជន ជាពិសេសដល់កសិករដែលចិញ្ចឹមគោនៅទីវាល។

Draft

រូបភាព៥.១០៖ ឯកឧត្តម វ៉ី សំណាង ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.២ ការបញ្ចេញមតិយោបល់របស់អនុប្រធានមន្ទីរបរិស្ថាន

លោក ហេង គួន ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ បានមានមតិយោបល់ចំពោះការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- នៅពេលដែលខ្សែអគ្គិសនីអូសឆ្លងកាត់ឧទ្យានជាតិ ខាងអគ្គិសនី ត្រូវសុំការអនុញ្ញាតពីឧទ្យានជាតិ ព្រោះឧទ្យានជាតិស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងបរិស្ថាន។
- សុវត្ថិភាពបង្គោលគួរធ្វើរបង និងដាក់ស្លាកសញ្ញាឆ្លងកាត់ព្រោះធ្លាប់មានបទពិសោធន៍កន្លងមកដោយប្រជាជនឆក់ស្លាប់។
- ចំពោះចន្លោះបង្គោល ៤០០ទៅ៤៥០ អាចដួលប៉ះពាល់ដល់ប្រជាជន នៅពេលដែលមានខ្យល់ខ្លាំង។ ដូច្នេះក្រុមហ៊ុនគួរមានវិធានការយ៉ាងណាចំពោះបញ្ហានេះ។

Draft

រូបភាព៥.១១៖ លោក ហេង គួន ប្រធានមន្ទីរបរិស្ថាន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៣ ការបញ្ចេញមតិយោបល់របស់អភិបាលរងស្រុកភ្នំស្រួច

លោក ស៊ួន សារ៉ុន អភិបាលរងស្រុកភ្នំស្រួច បានមានមតិយោបល់ ចំពោះការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកបានលើកឡើងជាសំនួរ និងសំណើចំនួន៣ ដែលទី១ លោកចង់ឱ្យបញ្ជាក់ឱ្យបានច្បាស់ចំពោះទំហំបង្គោលនីមួយៗ មានទំហំប៉ុន្មាន? និងទី២ សូមឱ្យក្រុមហ៊ុនធ្វើការបណ្តុះបណ្តាលប្រជាជនឱ្យបានដឹង និងកំឱ្យមាន ការភ័យខ្លាចនឹងគម្រោងនេះ។
- ទី៣ ក្រុមហ៊ុនគួរតែបំពាក់សំណាញ់ដើម្បីបាំងកុំឱ្យក្មេងឡើងលេងលើបង្គោល ដែលនាំឱ្យមានការគ្រោះថ្នាក់។



រូបភាព៥.១២៖ លោក ស៊ូន សារ៉ុន អភិបាលរងស្រុកភ្នំស្រួច ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៤ ការបញ្ចេញមតិយោបល់របស់ប្រធានអគ្គិសនីខេត្តកំពង់ស្ពឺ

លោក ពុត សុភ័ក ប្រធានអគ្គិសនីខេត្តកំពង់ស្ពឺ បានមានមតិយោបល់ជុំវិញការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- ជាគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងរ៉ែ និងថាមពល អគ្គិសនី កម្ពុជាបានសហការជាមួយក្រុមហ៊ុន Alex Corporation យ៉ាងជិតស្និត។

- ជាបទពិសោធន៍កន្លងមក បញ្ហាគ្រោះថ្នាក់របស់ប្រជាជនដែលឡើងលេង ឬប៉ះពាល់បង្គោលអគ្គិសនីតែងតែកើតមាន ទោះបីជាមានស្លាកសញ្ញាហាមឃាត់ក៏ដោយ។
- តាមគំនិតខ្ញុំការផ្សព្វផ្សាយ ដល់ប្រជាជនឱ្យមានដឹងលឺពីការគ្រោះថ្នាក់ដោយការឡើងលេង ឬប៉ះពាល់បង្គោលអគ្គិសនីនេះ។



Draft

រូបភាព៥.១៣៖ លោក ពុត សុភ័ក ប្រធានអគ្គីសនីខេត្ត ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៥ ការបញ្ចេញមតិយោបល់របស់ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ

លោក សួស សុផល អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ បានមានមតិយោបល់ចំពោះការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូន អគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកបានចោទជាសំនួរ ទាក់ទងនឹងបញ្ហាសម្លេងរំខាន ក្នុងពេលអនុវត្តន៍ ថាតើក្រុមហ៊ុនមានវិធានការយ៉ាងណាដើម្បីកាត់បន្ថយ កុំឱ្យមានការរំខានខ្លាំងដល់ ប្រជាជន និងសត្វព្រៃផងដែរ?